*Actus non facit reum nisi mens sit rea*
(The act itself does not constitute guilt unless done with a guilty intent)
Legal Maxims with Observations and Cases, 1878, p.25

ទ្រឹស្តីនេះ ពាក់ព័ន្ធជាចម្បងដល់នីតិវិធីព្រហ្មទណ្ឌ ដោយចែងថាអំពើនិងចេតនា កើតជាមួយគ្នា ដើម្បីបង្កើតជាបទល្មើសមួយ។ ទោះបីជាយ៉ាងនេះក្តី ក្នុងពេលខ្លះ ច្បាប់ចែងជាសាមញ្ញដោយទាញប្រយោលនូវចេតនាចេញពីអំពើ អនុលោមតាមទ្រឹស្តី *acta exteriora indicant iuteriora secreta* (អំពើខាងក្រៅបង្ហាញពីភាពសម្ងាត់ខាងក្នុង៖ External actions show internal secrets )។ នេះដូចជាករណីច្បាប់ចែងទាញចេតនាពីអំពើ ដែលត្រូវបានធ្វើដោយបំពានអំណាចស្របច្បាប់។ ឧទាហរណ៍ បុគ្គលម្នាក់មានអំណាចតាមច្បាប់ ក្នុងការអនុវត្តតួនាទីសាធារណៈ បានចូលទៅកាន់ស្ថានីយ៍រថភ្លើង ឬអគារសាធារណៈ រួចស្ថិតនៅក្នុងទីនោះ ប្រព្រឹត្តបទឧក្រិដ្ឋ។ ការចូលទៅនេះ ត្រូវបានសន្និតថា គាត់ចូលទៅជាមួយចេតនាប្រព្រឹត្តបទឧក្រិដ្ឋ។ ដូចគ្នានេះដែរ ករណីដែលតម្រួត (sheriff) ឬមន្ត្រីសាធារណៈ ប្រព្រឹត្តលើសអំណាច គាត់នឹងត្រូវបានចាត់ថាជាអ្នកទន្ទ្រានតាំងពីដំបូង (trespasser *ab initio*)។ សម្រាប់សកម្មភាពដែលត្រូវបានហាមឃាត់ ត្រូវបានធ្វើហើយទទួលយកថាបានធ្វើនោះ ចេតនាក្នុងការប្រព្រឹត្ត ត្រូវបានទាញចេញហើយ។

សម្រាប់បទល្មើសមនុស្សឃាត ក្នុងពេលប្រព្រឹត្តិ វាបង្ហាញឲ្យឃើញនូវអំពើនិងចេតនា។ អំពើសម្លាប់តែមួយ មិនបង្កើតនូវពិរុទ្ធភាពទេ លើកលែងធ្វើឡើងជាមួយចេតនាមានទោស (guilty intent)។ ទោះបីជាយ៉ាងនេះក្តី ចេតនាមានទោសនោះ ត្រូវបានសន្មត់ថាមាន។

បញ្ហាចេតនាទុច្ចរិត កើតមានជាចម្បងផងដែរ ក្នុងសកម្មភាពបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ (libel) ឬនិយាយបង្ខូចកេរ្តិ៍ (slander)។ គេបាននិយាយថា «*ការពិតកាន់តែច្រើន ការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ កាន់តែច្រើនដែរ*» នេះមានន័យថា ការពិតកាន់តែច្រើនត្រូវបានផ្សព្វផ្សាយ ការជឿកាន់តែច្រើន ហើយជាលទ្ធផល ការបរិហារកាន់តែមាន។ ដូចនេះ ការបោះពុម្ពនូវការពិតគ្មានការអនុញ្ញាត ឆ្លុះបញ្ចាំងពីចរិតមនុស្សនៃការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ។ ក៏ប៉ុន្តែ ការបោះពុម្ពឬសរសេរនៃខ្លឹមសារបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ ជារឿយៗ ជាប់ទាក់ទងនឹងចេតនាទុច្ចរិត របស់បុគ្គលមួយចំនួនឬអ្នកផ្សេង។ មានភាពខុសគ្នារវាង ការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរនិងនិយាយបង្ខូចកេរ្តិ៍។ និយាយជាទូទៅ ការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ ត្រូវបានសរសេរឬបោះពុម្ពនូវខ្លឹមសារបរិហារកេរ្តិ៍ ហើយការសរសេរឬបោះពុម្ពនូវខ្លឹមសារបរិហារកេរ្តិ៍ ជាការបង្ហាញពេញលេញនូវចេតនារបស់អ្នកសរសេរ ឬអ្នកបោះពុម្ពទៅកាន់សាធារណជន ហើយក្នុងករណីនោះ ចេតនាទុច្ចរិតក្នុងការផ្សព្វផ្សាយ ត្រូវបានពិចារណាដូចគ្នា

នឹងខ្លឹមសារនៃការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ ចេតនាទុច្ចរិតមិនមែនជាធាតុផ្សំចម្បង គាំទ្រសកម្មភាពនេះទេ។ ទោះបីជាយ៉ាងនេះក្តី សម្រាប់ការនិយាយបង្ខូចកេរ្តិ៍ ពាក្យប្រើប្រាស់ជារឿយៗ បង្ហាញពីការខឹងសម្បារ ទោះបីការ និយាយបង្ខូចកេរ្តិ៍អាចត្រូវប្តឹងបាន ប្រសិនបើការនិយាយ ជាមួយចេតនាទុច្ចរិត។ ក៏ប៉ុន្តែ ប្រសិនបើគ្មានចេតនាទុច្ចរិត កង្វះនូវការខូចខាតពិសេស វាមិនមែនជាកម្មវត្ថុសម្រាប់ប្តឹងទេ លើកលែង ពាក្យប្រើប្រាស់នាំដល់អ្នកផ្សេង (bystander) ទាញសន្និដ្ឋានថា ភាគីបង្ខូចកេរ្តិ៍ មានទោសពីបទល្មើសព្រហ្មទណ្ឌ ទោះបីគ្មានការខូចខាតពិសេស ក្នុងករណីនេះ ចេតនាត្រូវបានទាញ។

ក្នុងបណ្តឹងការបង្ខូចកេរ្តិ៍ជាលាយលក្ខណ៍អក្សរ ប្រឆាំងនឹងក្រុមហ៊ុនស្ថានីយរថភ្លើង វាត្រូវបានអះអាងថា បណ្តឹងអាចដំណើរការ ប្រសិនបើ ចេតនាក្នុងច្បាប់ អាចត្រូវបានទាញពីការបោះពុម្ពនៃខ្លឹមសារនៃការបង្ខូចកេរ្តិ៍។ វាត្រូវបានលើកឡើងផងដែរថាក្នុងការដាក់ទោសលើបទលួច វាមិនមានគ្រាន់តែចេតនាក្នុងការប្រព្រឹត្តទេ ក៏ប៉ុន្តែ មានផងដែរនូវមធ្យោបាយ អនុវត្តនាំឲ្យមានផលវិបាក។ អាស្រ័យហេតុដូចនេះ នៅពេលបុរសដាក់ដៃក្នុងហោប៉ៅរបស់អ្នកណាមួយក្នុងចេតនាលួច វាមិនអាចត្រូវបានអះអាងថាជាការប៉ុនប៉ងលួចទេ ឲ្យតែមានអ្វីក្នុងហោប៉ៅ ដែលអាចត្រូវបានចាត់ថាជាទង្វើលួច។